

# គំនិតដ៏អស្ចារ្យរបស់សាណា

The Asia Foundation - Let’s Read

Chan Pisey

Let’s Read
The Asia Foundation



សាណា និង ចិន្តា អង្គុយចាំអៀកជ្រកក្រោមម្លប់ស្វាយមួយ។ ថ្ងៃក្តៅខ្លាំង ពួកគេមិនអាចលេងខាងក្រៅបានទេ។ សាណា សួរថា៖ ”តើឯងចង់ជិះកង់ទៅមាត់ទន្លេឲ្យត្រជាក់ខ្លួនបន្តិចទេ?” ចិន្តាឡើងលើកង់បណ្តើរ តបបណ្តើរថា ”ទៅ! ប៉ុន្តែមិនដឹងថាកង់អ្នកណាបែកទេថ្ងៃនេះ។”



តាមផ្លូវចុះទៅមាត់ទន្លេសម្បូរថ្មរដិបរដុប និងបន្លា។ អ្នកជិះមកទីនេះ តែងតែបែកកង់។ បន្ទាប់មក ពួកគេត្រូវបណ្ដើរកង់បែកទៅផ្ទះវិញ ដើម្បីឲ្យឪពុកម្ដាយជួយយកទៅប៉ះ។ សាណា ជាក្មេងចូលចិត្តដោះស្រាយបញ្ហា ប៉ុន្តែនាងមិនអាចដោះស្រាយរឿងនេះបានឡើយ។



ប៉ុន្តែថ្ងៃនេះក្តៅពេក គួរតែប្រថុយហើយ។ ពេលកំពុងជិះកង់ចុះទៅតាមផ្លូវ សាណា ស្រែកថា "តោះយើង! ប្រណាំងគ្នា! ចាំមើលអ្នកណាទៅដល់មាត់ទឹកមុន!"



ប៉ុន្តែពេលជិះបានតែមួយជុំ នាងមានអារម្មណ៍ថាកង់មុខដូចជាធូរ។ សាណា ស្រែកថា៖ ”ពុទ្ធោ! ទៀតហើយ! គ្រាន់តែចង់ឲ្យត្រជាក់ស្រួលខ្លួនបន្តិចក៏មិនបានដែរ!”



ដើម្បីកុំឲ្យកង់ធូរខ្យល់អស់ពិបាកបណ្តើរទៅផ្ទះ សាណា ក៏យកស្កុរកៅស៊ូញាត់ចូលរន្ធដែលធ្លាយនោះ។ នាងគិតថាគំនិតនេះចម្លែកបន្តិចមែន ប៉ុន្តែវាប្រហែលជាអាចជួយបាន។



ពេលបណ្តើរកង់ដល់ផ្ទះ សាណា ភ្ញាក់ព្រើត ព្រោះខ្យល់មិនទាន់ធូរអស់នៅឡើយ ។ នាងក៏យករូបបកបិទទៅបិទលើស្គរកៅស៊ូដែលប្រឡាក់ដីបណ្តើរ និយាយបណ្តើរ "អស្ចារ្យ! ប៉ុន្តែគួរតែបន្ថែមរូបបិទញញឹមបែបនេះ"



សាណា សប់កង់ ហើយនាងសង្កេតឃើញថា ស្ករកៅស៊ូ និង
រូបបកបិទ ជួយទប់ខ្យល់ក្នុងកង់មិនឲ្យធ្លាយចេញបានយ៉ាង
ល្អ។ សាណា និយាយម្នាក់ឯងថា ”បើខ្ញុំមានរូបបកបិទស្អិតល្អ
ជាងនេះ ខ្ញុំអាចប៉ះកង់ដោយខ្លួនឯង នៅគ្រប់ពេល និងគ្រប់
ទីកន្លែង។”



ពេលត្រឡប់ពីមាត់ទន្លេមកផ្ទះវិញ ចិន្តា បានឆៀងចូលលេង សាណា។ ចិន្តា សួរ ”មើលទៅទំនងណាស់! តើវាជួយទប់ខ្យល់បានទេ?” សាណា តបថា ”ប្រាកដណាស់!” ពេលជិះកង់ចេញទៅ ចិន្តាស្រែកប្រាប់ថា ”ខ្ញុំគិតថាបើមានរូបបកបិទនេះលក់ នឹងមានមនុស្សចង់ទិញជាមិនខាន!”



សាណា គិតថា "តើធ្វើបែបនេះអាចរកលុយបានមែនឬ? ខ្ញុំអាចចាប់ផ្ដើមរកស៊ី ហើយក្លាយជាអ្នកមានមិនខាន!"



ពេលកំពុងទទួលទានអាហារពេលល្ងាច ពូនិមល បាននិយាយពីផែនការពង្រីកជំនួញខាងបោះពុម្ពផ្សាយ របស់គាត់។ សាណានិយាយដោយត្រេកអរថា "ខ្ញុំក៏បើកមុខរបរមួយដែរ! ខ្ញុំនឹងផលិតរូបបកបិទប៉ះកង់ សម្រាប់ក្មេងៗអាចប៉ះកង់បានដោយខ្លួនឯងបានគ្រប់ទីកន្លែង។"



ពូនិមល ក៏យល់ស្របថាគំនិតនេះអស្ចារ្យ។ គាត់សួរថា ”តើក្មួយដឹងទេថា ដើម្បីផលិតកៅស៊ូប៉ះត្រូវចំណាយអស់ប៉ុន្មាន? ហើយត្រូវលក់វាថ្លៃប៉ុន្មាន?” ពូនិមល បន្ថែមទៀតថា ”ក្រៅពីនេះ ក្មួយក៏ត្រូវចេះកត់ត្រាបញ្ជីត្រួតពិនិត្យទំនិញ ការលក់ និងការធ្វើទីផ្សារផងដែរ!” សាណា សម្លឹងចានបាយរបស់នាង។ នាងមិនទាន់បានគិតដល់ចំណុចខាងលើនេះទេ។



បន្ទាប់មកនាង ងើបមុខឡើង ហើយនិយាយទៅកាន់ពូនិមល ដោយញញឹមថា ”ខ្ញុំមិនចេះទេ! ប៉ុន្តែតើពូអាចជួយខ្ញុំបានទេ? ស្តាប់ទៅពិតជាសប្បាយណាស់!” និមល ក៏អស់សំណើច ហើយលាន់មាត់ថា ”ក្មួយប្រាកដជាក្លាយជាអ្នកជំនួញ ដូចពូមិនខាន។” សាណាតប ”ស្អីគេពូ? ខ្ញុំគ្រាន់តែចង់លក់រូបបកបិទប៉ះកង់ទេតើ។”



និមល តបវិញថា ”ក្មួយមានគំនិតល្អ ដែលអាចដោះស្រាយបញ្ហារបស់មនុស្សជាច្រើន។ ហើយក្មួយចង់ប្រែក្លាយគំនិតនេះទៅជាជំនួញ នោះហើយជាកិច្ចការរបស់អ្នកជំនួញ។” បន្ទាប់ពីទទួលទានអាហាររួច ពូនិមល បានបង្ហាញ សាណា នូវតារាងមួយចំនួនសម្រាប់ជំនួញរបស់គាត់ ហើយពន្យល់ពីសារៈសំខាន់ដែលត្រូវដឹងអំពីថ្លៃដើមក្នុងការផលិតកៅស៊ូប៉ះកង់ និងការកំណត់តម្លៃលក់។ សាណា និយាយថា ”ខ្ញុំនឹងចាប់ផ្ដើមសួរមិត្តខ្ញុំពីតម្លៃដែលពួកគេចង់បាន។” ពូនិមល ក៏តបថា ”ល្អណាស់! នេះហើយជាការស្វែងយល់ទីផ្សារ”



ថ្ងៃបន្ទាប់ សាណា ចុះទៅសាកសួរយោបល់ពីមិត្តរបស់នាង។ អ្នកខ្លះថា ពួកគេមិនចង់ទិញកៅស៊ូប៉ះកង់ទេ ប៉ុន្តែអ្នកភាគច្រើនរីករាយនឹងទិញវាក្នុងតម្លៃពីរឬបីពាន់រៀល។





សាណា ទូរសព្ទប្រាប់ពូរបស់នាងអំពីអ្វីដែលនាងទទួលបាន។ គាត់ក៏តបថា "ល្អណាស់! ឥឡូវក្មួយដឹងហើយថា ត្រូវលក់ក្នុងតម្លៃប៉ុន្មាន។" នាង ក៏ប្រាប់បន្ថែមទៅកាន់ ពូនិមល ថា "ខ្ញុំបានចុះទៅហាងលក់កង់ដើម្បីរកមើលកៅស៊ូប៉ះកង់ធម្មតា។" "ល្អ! កៅស៊ូប៉ះកង់ធម្មតា ជាទំនិញដែលគេអាចទិញប្រើ ក្រៅពីរូបបកបិទប៉ះកង់របស់ក្មួយ។"



សាណា ត្រូវបញ្ចុះបញ្ចូលសិស្សនៅសាលាឲ្យទិញរូបបកបិទប៉ះកង់របស់នាង។ ប៉ុន្តែតើនាងត្រូវធ្វើដូចម្តេច? នាងក៏គិតរកវិធីផ្សព្វផ្សាយមួយដ៏ល្អបំផុតដើម្បីឲ្យសិស្សទាំងអស់ដឹងពីគុណភាព រូបបកបិទប៉ះកង់របស់នាង ថាវាល្អបែបណាពេលក្មេងៗបិទលើកង់ពួកគេ។ សាណា សម្រេចចិត្តចែករូបបកបិទប៉ះកង់របស់នាងដល់មិត្តរួមថ្នាក់នាងមួយចំនួនប្រើដោយមិនគិតថ្លៃ ហើយសុំឲ្យពួកគេបិទវាលើកង់របស់ពួកគេ។





មិនយូរប៉ុន្មាន គំនិតនេះ ក៏បានលទ្ធផល! សិស្សម្នាក់ៗចង់បានរូបបកបិទប៉ះកង់របស់នាងមកប្រើ។ ហាងកង់នៅក្នុងភូមិក៏បានទិញទៅមួយចំនួនដែរ។ ប៉ុន្តែ សាណា ចាប់ផ្តើមរវល់យ៉ាងខ្លាំង។ នាងលែងមានពេលសប្បាយដូចការគិតទៀតហើយ។



ពូរបស់នាង ក៏ណែនាំថា "ប្រសិនបើ ក្មួយកុំព្យាយាមធ្វើគ្រប់យ៉ាងតែម្នាក់ឯង ក្មួយប្រហែលជាមិនសូវហត់បែបនេះទេ។" ភ្លាមនោះ សាណា ក៏នឹកឃើញដល់ ចិន្តា។ ចិន្តាជាក្មេងមានរបៀប ពូកែគណិតវិទ្យា និងចូលចិត្តកង់។ នាងនឹងក្លាយជាដៃគូជំនួញដ៏ល្អបំផុត។ ចិន្តា ពេញចិត្តនឹងគំនិតនេះណាស់! មិនយូរប៉ុន្មាន មិត្តទាំងពីរក៏ជួយគ្នាពង្រីកជំនួញកាន់តែធំ។ សាណា ធ្វើឲ្យគ្រប់គ្នាចាប់អារម្មណ៍ចំពោះរូបបកបិទកៅស៊ូប៉ះកង់របស់នាង ឯចិន្តាវិញ ជាអ្នកកត់ត្រាការទិញលក់។ សិស្សទាំងអស់ក្នុងភូមិនោះ សុទ្ធតែជិះកង់ដោយមានរូបបកបិទពណ៌ស្រស់ឆើតឆាយ។



ប៉ុន្មានខែក្រោយមក ពូនិមល បានមកលេងម្តងទៀត។ សាណា និង ចិន្តា បានប្រាប់គាត់ពីជំនួញរបស់ពួកគេ។ ចិន្តា បង្ហាញអំពីបញ្ជីលក់ និងកត់ត្រាទំនិញ ចំណែកឯ សាណា វិញបង្ហាញពីផែនការទីផ្សារ និងគំនិតច្នៃប្រឌិតថ្មី។



ពូនិមល និយាយថា "ក្មួយទាំងពីរជាអ្នកជំនួញដ៏អស្ចារ្យ!" "ចាស៎ អរគុណពូ! បើគ្មានពូជួយទេ ខ្ញុំប្រហែលមិនអាចធ្វើឲ្យគំនិតចម្លែកនេះក្លាយទៅជាជំនួញបានឡើយ។ តើពូចង់ស្តាប់ពីផែនការបន្ទាប់របស់ខ្ញុំទេ?"



Generously supported by Smart Axiata

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*គំនិតដ៏អស្ចារ្យរបស់សាណា (Darshana’s Big Idea)*, Author: The Asia Foundation - Let’s Read. Illustrator: Chan Pisey. Published by The Asia Foundation - Let’s Read, © The Asia Foundation - Let’s Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/